ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម

លេខ : 405 PEAC. អក

រាជធានីភ្នំពេញ , ថ្ងៃទី 08 ខែ ឧសភា ឆ្នាំ 2015

# សេចក្ដីជូនដំណឹង
## ស្ដីពី

ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់វិក្កយបត្រទាវប្រាក់ចំនួន 5,217,000 សន្លឹក
ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/ សហគ្រាស ( គិតទាំងសហគ្រាស ឯកត្តបុគ្គល ) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់វិក្កយបត្រចំនួន 5,217,000 សន្លឹក ជូននាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាស័យដ្ឋាន : ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី 08 ខែ ឧសភា ឆ្នាំ 2015 តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website : www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង 14:00 ថ្ងៃទី 10 ខែ មិថុនា ឆ្នាំ 2015 ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង 15:30 ថ្ងៃទី 10 ខែ មិថុនា ឆ្នាំ 2015 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន :
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ

ELECTRICITE DU CAMBODGE